ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិសុខភាពសាធារណៈ
ចូល
លេខ......៩៦១..........
មកដល់ថ្ងៃ..០៣..១១..២៥..
ម៉ោង...........................

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
លេខ : ......៤៧៧០......បទ.............

ថ្ងៃសុក្រ ១០កើត ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៥

## សូមជម្រាបជូន
## ឯកឧត្តមសាស្ត្រាចារ្យ នាយកវិទ្យាស្ថានជាតិសុខភាពសាធារណៈ

**កម្មវត្ថុ** : ស្តីពីការរៀបចំ **"វេទិការដ្ឋាភិបាលឌីជីថលឆ្នាំ២០២៥ និងព្រឹត្តិការណ៍ជាតិ-អន្តរជាតិពាក់ព័ន្ធ"** ចាប់ពីថ្ងៃទី៥ ដល់ថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២៥ នៅមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ។

**យោង** : លិខិតលេខ១៣២៩ សជណ.ពប ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តមសាស្ត្រាចារ្យ** ជ្រាបថា ស្របតាមការសម្រេចដ៏ខ្ពង់ខ្ពស់របស់ប្រមុខរាជរដ្ឋាភិបាល ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ (**ក.ប.ទ.**) នឹងរៀបចំ **"វេទិការដ្ឋាភិបាលឌីជីថលឆ្នាំ២០២៥ និងព្រឹត្តិការណ៍ជាតិ-អន្តរជាតិពាក់ព័ន្ធ"** ក្រោមប្រធានបទ **ការពន្លឿនអនាគតឌីជីថល៖ អភិបាលកិច្ច កំណើន និងភាពជាដៃគូសកល** រយៈពេល ៣ថ្ងៃ គឺចាប់ពីថ្ងៃទី៥ ដល់ថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២៥ នៅមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ។ វេទិកាឆ្នាំ២០២៥ នេះ នឹងរៀបចំឡើងដោយរួមបញ្ចូលគ្នានូវព្រឹត្តិការណ៍សំខាន់ៗចំនួន៣ រួមមាន ១) វេទិកាចែករំលែកបទពិសោធពាក់ព័ន្ធនឹងដំណើរការនៃការធ្វើបរិវត្តកម្មឌីជីថល អភិបាលកិច្ចឌីជីថល និងបច្ចេកវិទ្យាឌីជីថលថ្មីៗ ជាពិសេសបច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត ២) ពិព័រណ៍បច្ចេកវិទ្យាឌីជីថលដែលបង្ហាញអំពីសមិទ្ធផល ផ្ទាល់និងកម្មវិធីរដ្ឋាភិបាលឌីជីថល (DGPs) និងដំណោះស្រាយឌីជីថលរបស់ក្រសួង ស្ថាប័ន ក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថល និងធុរកិច្ចថ្មីឌីជីថល និង ៣) ព្រឹត្តិការណ៍ជាតិនិងអន្តរជាតិអម (Side Event) វេទិការដ្ឋាភិបាលឌីជីថល ដែលសហការជាមួយអង្គការសហប្រជាជាតិសម្រាប់អាស៊ីនិងប៉ាស៊ីហ្វិក (UN-ESCAP) កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) អង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃសហប្រជាជាតិ (UNESCO) អង្គការយូនីសេហ្វ (UNICEF) សហភាពទូរគមនាគមន៍អន្តរជាតិ (ITU) ទីភ្នាក់ងារកិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ (GIZ) មូលនិធិសមាហរណកម្មជប៉ុន-អាស៊ាន (JAIF) និងមជ្ឈមណ្ឌលបច្ចេកវិទ្យា Plug and Play មកពីតំបន់ Silicon Valley សហរដ្ឋអាមេរិក ជាដើម។

ក្នុងន័យនេះ **ក.ប.ទ.** សូមស្នើសុំ **ឯកឧត្តមសាស្ត្រាចារ្យ** ដូចខាងក្រោម៖

១. សូមអញ្ជើញ **ឯកឧត្តមសាស្ត្រាចារ្យ** ដើម្បីចូលរួមកម្មវិធីបើក។

២. ចាត់ជនបង្គោលទទួលបន្ទុកបរិវត្តកម្មឌីជីថល ចំនួន ១នាក់ និងបុគ្គលិកជំនាញ ចំនួន ១នាក់ ដើម្បីចូលរួមសិក្ខាសាលារយៈពេល ៣ថ្ងៃ។

៣. សូមជំរុញនិងផ្សព្វផ្សាយឱ្យទូលំទូលាយដល់អង្គភាពក្រោមឱវាទ ដើម្បីចូលរួមវេទិកាខាងលើនេះឱ្យបានច្រើនកុះករ ព្រមទាំងទទួលបានចំណេះដឹង បទពិសោធ និងឱកាសសាកល្បងប្រើប្រាស់ជាក់ស្តែងនូវឧបករណ៍បច្ចេកវិទ្យាថ្មីៗផងដែរ។

សូមផ្ជូនភ្ជាប់មកជាមួយនូវឯកសារទស្សនាទាននិងរបៀបវារៈនៃកម្មវិធីដូចមានក្នុង QR Code ខាងក្រោម។

សេចក្ដីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមសាស្ត្រាចារ្យ** ពិនិត្យនិងសម្រេចតាមការគួរ។

សូម **ឯកឧត្តមសាស្ត្រាចារ្យ** ទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រពីខ្ញុំ។

**ជ.រដ្ឋមន្ត្រី**

**រដ្ឋលេខាធិការ**

**ជុន វ៉ាត**

**សម្លៀកបំពាក់ក្នុងពិធីបើកនិងពិធីបិទ៖**

- បុរស "អាវធំ-ក្រវាត់ក"
- នារី "ប្រពៃណី"

**មន្ត្រីទំនាក់ទំនង** (តេឡេក្រាម)៖

- លោក **ប្រាក់ ស៊ីថុ** ទូរសព្ទលេខ ០៩២ ៨៨៦ ២៤២
- កញ្ញា **សោម រស្មី** ទូរសព្ទលេខ ០៨១ ៩០៥ ០៥១

https://go.gov.kh/mptc/dgf2025-doc

GO.gov.KH

សូមមេត្តាស្កេន QR Code
ដើម្បីទាញយកឯកសារ

https://go.gov.kh/mptc/event-dgf25

GO.gov.KH

សូមមេត្តាស្កេន QR Code
ដើម្បីចុះឈ្មោះយ៉ាងយូរត្រឹម
ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៥